សម្រាប់ការចេញផ្សាយភ្លាមៗ

# ប្រទេសជប៉ុន ផ្តល់ជំនួយបន្ថែម ដើម្បីលើកកម្ពស់ការខារតាមដាន និង ព្យាករណ៍កម្រិតទឹកទន្លេមេគង្គ

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១** – ថ្ងៃនេះ រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកា ២,៩ លានដុល្លារអាមេរិក ដល់គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) ដើម្បីគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្រ្តថ្មីរបស់ខ្លួន សំដៅលើកកម្ពស់ការអភិវឌ្ឍប្រកបដោយទំនួលខុសត្រូវនៅក្នុងតំបន់។

ទន្លេមេគង្គ និងដៃទន្លេនេះ បានផ្តល់របរចិញ្ចឹមជីវិត សន្តិសុខស្បៀង និងសេវាប្រព័ន្ធអេកូឡូស៊ីដ៏សម្បូរបែប ដល់ប្រជាជនប្រមាណ ៧០ លាននាក់ ដែលរស់នៅតាមដងទន្លេមេគង្គក្រោម។ បញ្ហាលំហូរទឹកទាបនៅដងទន្លេមេគង្គក្រោម កាលពីឆ្នាំ២០១៩ និង ឆ្នាំ២០២០ បានធ្វើឱ្យបណ្តាប្រទេសតាមដងទន្លេមេគង្គក្រោមទាំងអស់ រងផលប៉ះពាល់ជាច្រើន ដែលក្នុងនោះជីវភាពរស់នៅរបស់ប្រជាជនត្រូវបានរំខាន។

ថ្លែងនៅក្នុងពិធីចុះហត្ថលេខា ដែលបានប្រារព្ធនៅទីស្នាក់ការកណ្តាលនៃលេខាធិការដ្ឋាន MRC ក្នុងទីក្រុងវៀងចន្ទ លោកបណ្ឌិត អាន ពេជ្រហត្ថដា ដែលជានាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC បានគូសបញ្ជាក់ថា៖ “ថវិកាជំនួយថ្មីនេះ គឺផ្តល់ចំកន្លែងស្នូលនៃបញ្ហាដែលតំបន់យើងជួបប្រទះ ហើយក៏រំពឹងថានឹងត្រូវប្រឈមនាពេលអនាគត”។

ជំនួយនេះ គឺសម្រាប់រយៈពេល ៤ ឆ្នាំ ដោយគិតចាប់ពីឆ្នាំនេះ ដល់ឆ្នាំ២០២៤។ គេរំពឹងថា ថវិកានេះ នឹងជួយបង្កើនសមត្ថភាពតាមដាន និងវាយតម្លៃបរិស្ថានទន្លេ និងសម្របទៅនឹងការប្រែប្រួលជាទូទៅ របស់ MRC និងប្រទេសជាសមាជិករបស់ខ្លួន រួមមាន ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។

សកម្មភាពសំខាន់ៗ ដែលគាំទ្រក្រោមជំនួយនេះ រួមមាន ការធ្វើឱ្យប្រសើរឡើងនូវបណ្តាញតាមដានទន្លេ និងសមត្ថភាពព្យាករណ៍ ក៏ដូចជាការបង្កើតនូវស្ថានីយតាមដានថ្មីៗ តាមដងទន្លេមេគង្គ។ ថវិកានេះ ក៏នឹងត្រូវប្រើប្រាស់ ដើម្បីធ្វើឱ្យព័ត៌មានសាធារណៈស្តីពីទឹកជំនន់ និងគ្រោះរាំងស្ងួតកាន់តែប្រសើរឡើង តាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាទំនើប ដោយធានាថា សហគមន៍ក្នុងស្រុក និងរដ្ឋាភិបាល ទទួលបានព័ត៌មានទាន់ពេលវេលា ដើម្បីអនុវត្តយន្តការកាត់បន្ថយផលប៉ះពាល់នានាឲ្យបានសមស្រប។

ជំនួយថ្មីនេះ គឺជាជំនួយបន្ថែមលើថវិកា ៣,៩ លានដុល្លារអាមេរិក ដែលប្រទេសជប៉ុនបានផ្តល់ដល់ MRC កាលពីឆ្នាំមុន ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធព្យាករណ៍ទឹកជំនន់ និងភាពរាំងស្ងួត។ ចាប់តាំងពីឆ្នាំ ២០០១ ក្នុងនាមជាដៃគូអភិវឌ្ឍន៍ដ៏យូរអង្វែងរបស់ MRC ជប៉ុនបានផ្តល់ជាថវិកាជំនួយជាង ២១ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ប្រព័ន្ធធារាសាស្រ្ត ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងបរិស្ថាន។

ឯកអគ្គរដ្ឋទូតជប៉ុន ប្រចាំនៅប្រទេសឡាវ លោក កៃហ្សូ តាកេវ៉ាកា (Keizo Takewaka) បានថ្លែងនៅឯពិធីចុះហត្ថលេខា នាថ្ងៃទី២៦ ខែកុម្ភៈនេះថា៖ “ថវិកាបន្ថែមនេះ នឹងជួយបង្កើនសមត្ថភាពរបស់ MRC ក្នុងការផ្តល់ឲ្យសាធារណៈជន និងប្រទេសជាសមាជិករបស់ខ្លួន នូវសេវាកម្មតាមដាន និងព្យាករណ៍ទឹកទន្លេឱ្យបានកាន់តែសុក្រិត និងមានប្រសិទ្ធភាពខ្ពស់ជាងមុន”។

ប្រទេសជប៉ុន គឺជាដៃគូអភិវឌ្ឍន៍មួយក្នុងចំណោមដៃគូជាច្រើន ដែលគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រថ្មីរបស់ MRC។ ផែនការរយៈពេល ៥ ឆ្នាំនេះ គឺជាឧបករណ៍ដ៏សំខាន់មួយ ក្នុងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេសម្រាប់ឆ្នាំ ២០២១-២០៣០ ហើយវាក៏នឹងផ្តល់លទ្ធភាពឱ្យប្រទេសសមាជិកទាំងបួនថែរក្សាបាននូវមុខងារអេកូឡូស៊ីទន្លេ និងពង្រឹងភាពធន់ទៅនឹងមហន្តរាយនានាផងដែរ។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជាជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីអភិវឌ្ឍន៍តំបន់នេះប្រកបដោយចីរភាព។

**ចប់**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក មាស សុភក្រ្ត មន្ត្រីទំនាក់ទំនងសម្រាប់អ្នកសារព័ត៌មាន
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរសព្ទដៃ៖ +856-20-77779168

###